# ឯកសារទស្សនាទាន

## ការកសាងភាពធន់នឹងគ្រោះរាំងស្ងួតនៅអាស៊ីអាគ្នេយ៍
## កិច្ចសន្ទនាជាន់ខ្ពស់ជាមួយភាគីពាក់ព័ន្ធថ្នាក់ជាតិ ស្តីពីគោលនយោបាយគ្រោះរាំងស្ងួតនៅកម្ពុជា

សណ្ឋាគារ រ៉ាហ្វលឡឺរ៉ូយ៉ាល់
រាជធានីភ្នំពេញ
ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

## សេចក្តីផ្តើម

របាយការណ៍គ្រោះមហន្តរាយអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩ បានបង្ហាញថា ការបាត់បង់លើតម្លៃសេដ្ឋកិច្ចប្រចាំឆ្នាំនៅអាស៊ីនិងប៉ាស៊ីហ្វិក ច្រើនជាង០៤(បួន)ដង ខណៈដែលមានគ្រោះមហន្តរាយ សភាពយឺតៗ ជាពិសេសគ្រោះរាំងស្ងួត បានបង្កហានិភ័យគ្រោះមហន្តរាយបន្ថែម ទៅក្នុងភូមិសាស្ត្ររបស់តំបន់។ ការបាត់បង់ថវិកាជាមធ្យមប្រចាំឆ្នាំ ក្នុងតំបន់មានចំនួន **៦៧៥** ពាន់លានដុល្លារ ក្នុងនោះ ចំនួន**៤០៥**ពាន់លានដុល្លារ ស្មើនឹង **៦០** ភាគរយ គឺជាការបាត់បង់លើផ្នែកកសិកម្ម ទាក់ទងទៅនឹងគ្រោះរាំងស្ងួត។ ការបាត់បង់លើតម្លៃសេដ្ឋកិច្ច ដោយសារគ្រោះមហន្តរាយ ការប៉ាន់ស្មានពីមុនមានទំហំធំជាង ដោយការបាត់បង់បន្ថែម ភាគច្រើនទាក់ទងនឹងផលប៉ះពាល់ដោយគ្រោះមហន្តរាយ ដែលមានសភាពយឺតៗមកលើវិស័យកសិកម្ម។

នៅអាស៊ីអាគ្នេយ៍ ការបាត់បង់ថវិកាជាមធ្យមប្រចាំឆ្នាំ ចំនួន **៨៦.៥** ពាន់ លានដុល្លារ ស្មើនឹង **៦០** ភាគរយនៃចំនួនសរុបដោយគ្រោះរាំងស្ងួត។ ការបាត់បង់ថវិកាជាមធ្យមប្រចាំឆ្នាំ ក្នុងចំណោមប្រទេសដូចជា កម្ពុជា មីយ៉ាន់ម៉ា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ វៀតណាម និងហ្វីលីពីន មានកម្រិតខ្ពស់ជាងគេ។ នៅកម្ពុជា ការបាត់បង់ថវិកាជាមធ្យមប្រចាំឆ្នាំ គិតជាភាគរយ នៃផលិតផលក្នុងស្រុកសរុប គឺមាន **៨** ភាគរយ ដែលក្នុងនោះប្រមាណ **៥.៥** ភាគរយ បាត់បង់ដោយសារគ្រោះរាំងស្ងួតសិកម្ម។ ការបាត់បង់ផ្នែកកសិកម្ម ដោយគ្រោះរាំងស្ងួត គឺមាននៅគ្រប់ប្រទេស ទាំងអស់នៅក្នុងអាស៊ីអាគ្នេយ៍។ ដូច្នេះគ្មានប្រទេសណាមួយនៅអាស៊ីអាគ្នេយ៍ មិនអើពើនឹងគ្រោះរាំងស្ងួតកសិកម្មនោះឡើយ ខណៈពេលដែលការកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច ដោយគ្រោះមហន្តរាយ។ លើសពីនេះទៀត គ្រោះរាំងស្ងួតក្នុងវិស័យកសិកម្ម មិនត្រឹមតែបង្កឱ្យមានការបាត់បង់លើតម្លៃសេដ្ឋកិច្ចដ៏ធំធេងប៉ុណ្ណោះទេ វាក៏បានផ្សារភ្ជាប់ជាមួយនឹង ការធ្លាក់ចុះនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គម ផងដែរ។

ការរកឃើញលទ្ធផលទាំងនេះ ធ្វើឲ្យមានពង្រឹងការសិក្សារួមគ្នា រវាងគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) និងលេខាធិការដ្ឋានអាស៊ាន ដោយមានការគាំទ្រពីគណៈកម្មាធិការអាស៊ានសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (ACDM)។ ការសិក្សានៅឆ្នាំ២០១៩ លើប្រធានបទ *"ត្រៀមរៀបចំសម្រាប់ឆ្នាំរាំងស្ងួត: ការកសាងភាពធន់ទៅនឹងគ្រោះរាំងស្ងួត នៅអាស៊ីអាគ្នេយ៍"* ព្យាករណ៍ថានឹងកើតឡើងមានគ្រោះរាំងស្ងួតនៅឆ្នាំខាងមុខ ជាពិសេសតំបន់ដែលរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត នឹងទំនងអាចកើតមានការផ្លាស់ប្តូរនិងមានវិសាលភាពកាន់តែធំជាងមុន ដែលធ្វើឱ្យមានប៉ះពាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព។ គ្រោះរាំងស្ងួត នឹងអាចកើតឡើងដោយជៀសមិនផុត និងមានផលប៉ះពាល់ជាច្រើន ប្រសិនបើកិច្ចអន្តរាគមន៍

មិនទាន់ពេលវេលា។ លទ្ធផលនៃការសិក្សានេះ ត្រូវបានផ្សព្វផ្សាយនៅឯកិច្ចប្រជុំរបស់គណៈកម្មាធិការអាស៊ានសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ លើកទី៣៤ នាខែមេសា ឆ្នាំ២០១៩ ដែលរៀបចំដោយ រដ្ឋាភិបាលមីយ៉ាន់ម៉ា នៅទីក្រុងម៉ាន់ដាឡេ។ នៅអំឡុងពេលផ្សព្វផ្សាយលទ្ធផលនៃការសិក្សានេះ ប្រតិភូជាច្រើនបានផ្តល់ជាយោបល់ថា គួរមានកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធចម្រុះនៅតាមប្រទេស ដែលពាក់ព័ន្ធរួមនឹងអ្នកមានសិទ្ធិសម្រេចចិត្តលើគោលនយោបាយ ដែលនឹងជួយផ្តល់ភាពបន្ទាន់ដល់គោលនយោបាយ និងបង្កើនសន្ទុះ ទៅលើសកម្មភាពអាទិភាពដែលជាតម្រូវការនៅថ្នាក់ជាតិ និងថ្នាក់តំបន់។

## គោលបំណង

កិច្ចសន្ទនានេះ នឹងចូលរួមដឹកនាំដោយមន្រ្តីបង្គោល នៃគណៈកម្មាធិការអាស៊ានសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (ACDM) តាមបណ្តាប្រទេសនីមួយៗ និងកិច្ចសន្ទនាជាមួយពហុភាគីពាក់ព័ន្ធ នឹងត្រូវបានរៀបចំឡើងនៅក្នុងប្រទេសចំនួន៤(បួន) លើប្រធានបទ ត្រៀមរៀបចំការសិក្សាសម្រាប់ផ្ទាំរាំងស្ងួត មានដូចជា ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងវៀតណាម។

កិច្ចសន្ទនាជាមួយពហុភាគីពាក់ព័ន្ធលើគ្រោះរាំងស្ងួតនេះ នឹងប្រារព្ធធ្វើឡើង ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម** ទេសរដ្ឋមន្រ្តី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងមានការចូលរួម ដោយមន្រ្តីរាជរដ្ឋាភិបាលជាន់ខ្ពស់ ពីក្រសួងស្ថាប័ន ភាគីពាក់ព័ន្ធចម្រុះ ក្នុងគោលបំណង៖

១. ចលនាការយកចិត្តទុកដាក់ លើភាពបន្ទាន់ នៃការដោះស្រាយគ្រោះរាំងស្ងួត
២. ប្រាស្រ័យទាក់ទង លើការត្រៀមរៀបចំសម្រាប់ផ្ទាំរាំងស្ងួត ផ្សព្វផ្សាយពីការរកឃើញ សំខាន់ៗពីការសិក្សា ចែកជូនដល់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ផ្សេងទៀត
៣. គូសបញ្ជាក់ពីទស្សនៈវិស័យ របស់ភាគីពាក់ព័ន្ធផ្សេងៗ ចំពោះការកើតឡើងនៃគ្រោះរាំងស្ងួត ផលប៉ះពាល់ និងដំណោះស្រាយ
៤. ឯកភាពលើជំហានបន្ទាប់ សម្រាប់សកម្មភាពនិងយុទ្ធសាស្រ្ត យ៉ាងទូលំទូលាយនៅកម្រិតអាស៊ាន សម្រាប់ការកសាងភាពធន់នឹងគ្រោះរាំងស្ងួត៖ សេចក្តីថ្លែងការណ៍អាស៊ាន និងផែនការសកម្មភាពអាស៊ាន។